**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

លេខ ០០១ សកចន

ថ្ងៃព្រហ ១រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០

## សេចក្តីអំពាវនាវ

## ស្តីពី ការត្រៀមលក្ខណៈសម្បត្តិរបស់សេវាកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ក្នុងការងើបឡើងវិញ(Recovery) ក្រោយវិបត្តិនៃវីរុសរលាកផ្លូវដង្ហើមប្រភេទថ្មី (Post Covid-19)

ក្រសួងទេសចរណ៍ មានកិត្តិយសសូមជម្រាបជូនដល់ម្ចាស់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាបថា ក្រសួងទេសចរណ៍មានចក្ខុវិស័យសុទិដ្ឋិនិយមថាវិស័យទេសចរណ៍កម្ពុជានឹងវិលត្រឡប់ទៅរកភាពប្រសើរឡើងវិញ ក្រោយវិបត្តិនៃការរីករាលដាលជាសកលនៃវីរុសរលាកផ្លូវដង្ហើមប្រភេទថ្មី (Post Covid-19) ស្របតាមយុទ្ធនាការ “Stay Home Today, Travel Tomorrow”។ ក្នុងបរិបទនេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិនឹងមានតម្រូវការកាន់តែខ្ពស់នូវគុណភាពសេវាកម្ម ជាពិសេសការយកចិត្តទុកដាក់ចំពោះអនាម័យ សុវត្ថិភាព សេវាកម្ម និងផលិតផលទេសចរណ៍។

ក្នុងដំណាក់កាលអន្តរកាលនៃការរង់ចាំ ស្ថានភាពថយចុះនៃការរីករាលដាលជាសកលនៃវីរុសរលាកផ្លូវដង្ហើមប្រភេទថ្មី (Covid-19) ក្រសួងទេសចរណ៍សូមអំពាវនាវដល់ម្ចាស់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ទាំងអស់ត្រៀមលក្ខណៈសម្បត្តិ ដោយពង្រឹងគុណភាពសេវាកម្មរបស់ខ្លួនឱ្យបានកាន់តែប្រសើរជាងមុន និងលើកទឹកចិត្តដល់ទីតាំងសណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍ទាំងឡាយ ដែលបានធ្វើប្រតិបត្តិការអាជីវកម្មចាប់ពី១០ឆ្នាំឡើងទៅ គួរឆ្លៀតក្នុងឱកាសនៃវិបត្តិជំងឺឆ្លងនេះ កែលម្អរជួសជុល ក្នុងករណីជាយថាហេតុណាមួយ ដើម្បីបង្កើនគុណភាព និងដូចជាលក្ខណៈសម្បត្តិដើម្បីអាចបង្កើនលទ្ធភាពទទួលបានការវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ក្នុងកម្រិតប្រសើរជាងមុន(**កើនលំដាប់ថ្នាក់ផ្កាយ**)។

ម្ចាស់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍អាចស្វែងយល់អំពីប្រព័ន្ធចំណាត់ថ្នាក់នេះ ព្រមទាំងអាចធ្វើការវាយតម្លៃសាកល្បង (Pre-Assessment) តាមរយៈគេហទំព័រ www.cambodiatourismrating.org/kh។

សូមស្កេន QR Code ខាងស្តាំនេះសម្រាប់ការវាយតម្លៃសាកល្បង

ក្រសួងទេសចរណ៍យល់ថា ប្រព័ន្ធចំណាត់ថ្នាក់នេះអាចប្រើប្រាស់ជាមូលដ្ឋានជំនួយស្មារតីដល់ការអនុវត្តជាក់ស្តែង។

ក្រសួងទេសចរណ៍ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ទាំងអស់នឹងចូលរួមអនុវត្តសេចក្តីអំពាវនាវខាងលើនេះប្រកបដោយការយកចិត្តទុកដាក់ខ្ពស់។

ក្រសួងទេសចរណ៍

ផ្ទះលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org